ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ១៥៤២ សហវ.ប្រកា.អគព

# ប្រកាស
# ស្ដីពី
# វិធាននិងនីតិវិធីសារពើពន្ធចំពោះបរធនបាលកិច្ច

## ឧបនាយករដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្ដីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្ដីពីការកែសម្រួល និងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្ដីពីការកែសម្រួល និងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២៣/០០១ ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០២៣ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥២៣/០០៤ ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០២៣ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីសារពើពន្ធ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១១៩/០០២ ចុះថ្ងៃទី២ ខែមករា ឆ្នាំ២០១៩ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីបរធនបាលកិច្ច
- បានឃើញអនុក្រឹត្យលេខ ៤៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA
mef.gov.kh
t.me/mefcambodia



ទូរស័ព្ទ: (+៨៥៥)២៣ ៨៩០ ៦៦៦
Phone: (+855) 23 890 666
info@mef.gov.kh
mef.cabinet@mef.gov.kh

## សេចក្ដីសម្រេច

**ប្រការ១ .-**

ប្រកាសនេះ មានគោលបំណងកំណត់អំពីវិធាននិងនីតិវិធីសារពើពន្ធចំពោះប្រតិបត្តិការបរធនបាលកិច្ច។

**ប្រការ២ .-**

ប្រកាសនេះ មានវិសាលភាពអនុវត្តចំពោះបរធនបាលទាយក បរធនបាល និងអត្ថគាហកៈ ជាអ្នកជាប់ពន្ធនិវាសនជនឬជាអ្នកជាប់ពន្ធអនិវាសនជនដែលធ្វើប្រតិបត្តិការពាក់ព័ន្ធនឹងបរធនបាលកិច្ចដែលបានបង្កើតនៅក្នុងព្រះរាជាណាចក្រកម្ពុជា វៀរលែងតែបរធនបាលកិច្ចមានទម្រង់គតិយុត្តជាក្រុមហ៊ុនឬសហគ្រាស។

**ប្រការ៣ .-**

សម្រាប់គោលដៅនៃប្រកាសនេះ៖

១- ក្រុមហ៊ុនបរធនបាល សំដៅដល់ បរធនបាលជានីតិបុគ្គលដែលទទួលបានអាជ្ញាបណ្ណ និង/ឬការអនុញ្ញាតពីនិយ័តករបរធនបាលកិច្ចឱ្យធ្វើប្រតិបត្តិការបរធនបាលកិច្ចមួយឬច្រើន។

២- ទ្រព្យសម្បត្តិបរធនបាលកិច្ច សំដៅដល់ ទ្រព្យសម្បត្តិឬមូលនិធិដែលបានផ្ទេរទៅក្នុងបរធនបាលកិច្ច និងផលដែលបានពីទ្រព្យសម្បត្តិឬមូលនិធិនោះ។

៣- បរធន សំដៅដល់ ទ្រព្យសម្បត្តិឬមូលនិធិដែលបានផ្ទេរទៅឱ្យបរធនបាលគ្រប់គ្រង និងចាត់ចែងសម្រាប់ជាប្រយោជន៍ដល់អត្ថគាហកៈ តាមលក្ខខណ្ឌដែលកំណត់ដោយលិខិតបរធនបាលកិច្ចឬបទប្បញ្ញត្តិជាធរមាន។

៤- បរធនបាល សំដៅដល់ ក្រុមហ៊ុនបរធនបាលឬបរធនបាលជារូបវន្តបុគ្គលដែលទទួលសិទ្ធិគ្រប់គ្រងចាត់ចែងនិងថែរក្សាបរធនពីបរធនបាលទាយកឬអ្នកផ្ដល់វិភាគទានបរធនបាលកិច្ចសម្រាប់ជាប្រយោជន៍ដល់អត្ថគាហកៈ ដោយអនុលោមតាមលិខិតបរធនបាលកិច្ចឬបទប្បញ្ញត្តិជាធរមាន។

៥- បរធនបាលកិច្ច សំដៅដល់ កិច្ចការគ្រប់គ្រង និងចាត់ចែងបរធន ដែលផ្ដល់ដោយបរធនបាលទាយកសម្រាប់ជាប្រយោជន៍ដល់អត្ថគាហកៈ ដោយអនុលោមតាមលិខិតបរធនបាលកិច្ចឬបទប្បញ្ញត្តិជាធរមាន។

៦- បរធនបាលទាយក សំដៅដល់ បុគ្គលដែលបង្កើតនិងកំណត់លក្ខខណ្ឌនៃបរធនបាលកិច្ច និងផ្ដល់ទ្រព្យសម្បត្តិឬមូលនិធិដំបូងនៅក្នុងបរធនបាលកិច្ច។

៧- បរធនបាលរូបវន្តបុគ្គលឯករាជ្យ សំដៅដល់ រូបវន្តបុគ្គលដែលទទួលបានអាជ្ញាបណ្ណពីនិយ័តករបរធនបាលកិច្ចឱ្យធ្វើប្រតិបត្តិការបរធនបាលកិច្ចមួយឬច្រើន ហើយបរធនបាលរូបវន្តបុគ្គលឯករាជ្យនេះ មិនស្ថិតនៅក្រោមលក្ខខណ្ឌអាជ្ញាបណ្ណរបស់ក្រុមហ៊ុនបរធនបាលណាមួយឡើយ។

៨- ប្រតិបត្តិការបរធនបាលកិច្ច សំដៅដល់ ការធ្វើប្រតិបត្តិការបរធនបាលកិច្ចដោយបរធនបាល ឬអ្នកចូលរួមដទៃទៀតទៅតាមប្រភេទបរធនបាលកិច្ច រួមមាន បរធនបាលកិច្ចសាធារណៈ បរធនបាលកិច្ចហិរញ្ញវត្ថុ បរធនបាលកិច្ចពាណិជ្ជកម្ម បរធនបាលកិច្ចសង្គម និងបរធនបាលកិច្ចបុគ្គល។ បរធនបាល ឬអ្នកចូលរួមដទៃទៀតដែលអាចធ្វើប្រតិបត្តិការបរធនបាលកិច្ចទាំងនេះ ត្រូវទទួលបានអាជ្ញាបណ្ណឬការអនុញ្ញាតឬការចុះបញ្ជីពីនិយ័តករបរធនបាលកិច្ច។

៩- លិខិតបរធនបាលកិច្ច សំដៅដល់៖

ក- លិខិតគតិយុត្តដែលកំណត់ជាអាទិ៍អំពីការបង្កើត ការគ្រប់គ្រង ការចាត់ចែង និងការបញ្ចប់បរធនបាលកិច្ច ដែលត្រូវបានធ្វើឡើងរវាងបរធនបាលទាយកឬអ្នកផ្តល់វិភាគទានបរធនបាលកិច្ច និងបរធនបាលដោយមានការបញ្ជាក់ពីសារការីឬមេឃុំ/សង្កាត់ឬដោយបុគ្គលផ្សេងទៀតដែលមានចែងក្នុងបទប្បញ្ញត្តិជាធរមាន។

ខ- មតកសាសន៍ដែលធ្វើឡើងស្របតាមបទប្បញ្ញត្តិស្តីពីសន្តតិកម្មនៃក្រមរដ្ឋប្បវេណី។

១០-សេវារក្សាទុក សំដៅដល់ ការផ្ទេរទ្រព្យសម្បត្តិឬមូលនិធិដោយបុគ្គលណាមួយ ទៅឱ្យបរធនបាលដើម្បីរក្សាទុក ហើយប្រគល់ទៅឱ្យបុគ្គលផ្សេងទៀតឬប្រគល់ត្រឡប់ទៅឱ្យបុគ្គលនោះវិញ តាមលក្ខខណ្ឌដែលបានកំណត់នៅក្នុងលិខិតបរធនបាលកិច្ច។

១១-អត្ថគាហកៈ សំដៅដល់ បុគ្គលដែលទទួលផលប្រយោជន៍ពីបរធនបាលកិច្ច។

១២-អ្នកផ្តល់វិភាគទានបរធនបាលកិច្ច សំដៅដល់ បុគ្គលដែលផ្តល់វិភាគទាននៅក្នុងបរធនបាលកិច្ច ឬបរធនបាលកិច្ចដែលមានស្រាប់ និងមានសិទ្ធិចូលរួមកំណត់លក្ខខណ្ឌនៃការបង់វិភាគទានដែលនឹងត្រូវគ្រប់គ្រងនិងចាត់ចែងដោយបរធនបាល និងលក្ខខណ្ឌនៃការទទួលផលរបស់អត្ថគាហកៈ។

**ប្រការ៤ ._**

ប្រភេទបរធនបាលកិច្ចចម្បងៗ មានដូចខាងក្រោម៖

១- បរធនបាលកិច្ចសាធារណៈ ត្រូវបានបង្កើតឡើងក្នុងគោលបំណងជាប្រយោជន៍របស់ប្រជាពលរដ្ឋខ្មែរទូទៅ។ បរធនបាលកិច្ចនេះ រួមមាន៖

ក- ការអភិវឌ្ឍវិស័យធនាគារ និងមីក្រូហិរញ្ញវត្ថុនៅកម្ពុជា នៅពេលដែល៖

- ដៃគូអភិវឌ្ឍន៍ផ្តល់ទ្រព្យសម្បត្តិ ឬមូលនិធិរបស់ខ្លួនសម្រាប់ជាប្រយោជន៍របស់ប្រជាពលរដ្ឋខ្មែរ ហើយទ្រព្យសម្បត្តិ ឬមូលនិធិទាំងនោះបាននិងកំពុងគ្រប់គ្រងនិងចាត់ចែងនៅក្នុងគ្រឹះស្ថានធនាគារ និងមីក្រូហិរញ្ញវត្ថុ ឬបុគ្គលផ្សេងទៀត និង
- តាមលក្ខខណ្ឌដែលមានកំណត់នៅក្នុងលិខិតបរធនបាលកិច្ចឬបទប្បញ្ញត្តិជាធរមាន។

ខ- ជាប្រយោជន៍សាធារណៈផ្សេងទៀតនៅពេលដែលបញ្ញត្តិករពាក់ព័ន្ធតែងតាំងបរធនបាលដើម្បីគ្រប់គ្រង និងការពារមូលនិធិនានាតាមលក្ខខណ្ឌដែលកំណត់ដោយលិខិតបរធនបាលកិច្ចឬបទប្បញ្ញត្តិជាធរមាន។ លក្ខខណ្ឌទាំងនេះមានជាអាទិ៍៖

- មូលនិធិដែលបានផ្តល់ឱ្យរាជរដ្ឋាភិបាល ឬត្រូវបានផ្តល់ដោយរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ដើម្បីបំពេញគោលបំណងជាក់លាក់ណាមួយរបស់អ្នកផ្តល់ជំនួយ ហើយអ្នកផ្តល់ជំនួយទាមទារឱ្យមូលនិធិនេះ ត្រូវបានចាត់ចែងប្រើប្រាស់និងអាស្រ័យផលស្របតាមគោលបំណងរបស់ខ្លួន ឬ
- ត្រូវការពារផលប្រយោជន៍របស់កុមារឬអសមត្ថជនផ្សេងទៀត ឬ
- មត៌កដែលធ្លាក់ទៅជាទ្រព្យរដ្ឋតាមបទប្បញ្ញត្តិជាធរមាន។

២- បរធនបាលកិច្ចពាណិជ្ជកម្ម ត្រូវបានបង្កើតឡើងក្នុងគោលបំណងស្វែងរកប្រាក់ចំណេញ សម្រាប់ជាប្រយោជន៍ដល់អ្នកផ្តល់វិភាគទានបរធនបាលកិច្ច ឬបុគ្គលណាមួយជាក់លាក់ដែលកំណត់ដោយអ្នកផ្តល់វិភាគទានបរធនបាលកិច្ច រួមមាន៖



ႠL

ក- មូលនិធិសោធននិវត្តន៍ មូលនិធិអប់រំ និងមូលនិធិប្រហាក់ប្រហែលផ្សេងទៀតដែលបុគ្គលណាមួយផ្ទេរទ្រព្យសម្បត្តិឱ្យបរធនបាល ហើយត្រូវបានផ្ទេរត្រឡប់ទៅឱ្យបុគ្គលនោះវិញឬផ្ទេរឱ្យបុគ្គលណាមួយផ្សេងទៀតនៅពេលដែលបានបំពេញតាមលក្ខខណ្ឌមួយចំនួនដូចខាងក្រោម៖

- មានការផ្ទេរទ្រព្យសម្បត្តិ ឬមូលនិធិទៅក្នុងបរធនបាលកិច្ចដោយបុគ្គលណាម្នាក់ឱ្យទៅបរធនបាលជាប្រចាំ ហើយបរធនបាលគ្រប់គ្រងនិងចាត់ចែងមូលនិធិនេះសម្រាប់ជាប្រយោជន៍ជាក់លាក់របស់បុគ្គលនេះឬបុគ្គលផ្សេងទៀត ហើយ
- នៅពេលដែលទ្រព្យសម្បត្តិ ឬមូលនិធិរបស់អ្នកផ្តល់វិភាគទានផ្សេងទៀត ត្រូវបានដាក់បញ្ចូលក្នុងគម្រោងវិនិយោគ ហើយត្រូវបានវិនិយោគដោយបរធនបាលសម្រាប់ជាប្រយោជន៍របស់អ្នកផ្តល់វិភាគទានទាំងអស់តាមលក្ខខណ្ឌដែលបានកំណត់ និង
- នៅពេលដែលទ្រព្យសម្បត្តិ និងផលដែលបានមកពីការវិនិយោគត្រូវបានកំណត់ គ្រប់គ្រង និងរាយការណ៍ដាច់ដោយឡែកទៅបុគ្គលនោះ។

ខ- សេវារក្សាទុកដែលក្នុងនោះមានការផ្ទេរទ្រព្យសម្បត្តិឬមូលនិធិដោយបុគ្គលណាមួយឱ្យទៅបរធនបាល ហើយបរធនបាលត្រូវផ្ទេរត្រឡប់ឱ្យទៅបុគ្គលនេះវិញ ឬឱ្យទៅបុគ្គលណាមួយផ្សេងទៀតនៅពេលដែលបានបំពេញតាមលក្ខខណ្ឌដូចខាងក្រោម៖

- មានការរក្សាទុកទ្រព្យសម្បត្តិឬមូលនិធិដោយបុគ្គលណាមួយ មានជាអាទិ៍ មន្ទីរសារការី ឬការិយាល័យមេធាវី ឬក្រុមហ៊ុនគណនេយ្យ ឬ
- មានការកាន់កាប់ទ្រព្យសម្បត្តិឬមូលនិធិតម្កល់ដើម្បីជាប្រយោជន៍របស់វិនិយោគិន អ្នកទិញអចលនវត្ថុ និងដើម្បីប្រតិបត្តិការពាណិជ្ជកម្មផ្សេងៗទៀត ឬ
- សេវារក្សាទុកផ្សេងទៀតដែលទទួលបានការអនុញ្ញាតតាមសេចក្តីសម្រេចរបស់បញ្ញត្តិករផ្សេងទៀត មានជាអាទិ៍ ធនាគារជាតិនៃកម្ពុជា និយ័តករមូលបត្រកម្ពុជា ឬក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីគ្រប់គ្រងសកម្មភាពនានាដែលស្ថិតក្រោមតួនាទីនិងភារកិច្ចរបស់ខ្លួន។

គ- គម្រោងភាគហ៊ុននិយោជិតឬផលប្រយោជន៍និយោជិត នៅពេលដែលបរធនបាលគ្រប់គ្រងទ្រព្យសម្បត្តិ ឬមូលនិធិ ដើម្បីវិនិយោគក្នុងនាមនិយោជិតនោះ និង

ឃ- ដើម្បីគោលបំណងផ្សេងទៀត៖

- នៅពេលដែលមានការផ្ទេរទ្រព្យសម្បត្តិ ឬមូលនិធិដោយបុគ្គលណាមួយឱ្យទៅបរធនបាលសម្រាប់ជាប្រយោជន៍ដល់អ្នកផ្តល់វិភាគទានឬបុគ្គលផ្សេងទៀតដែលកំណត់ដោយអ្នកផ្តល់វិភាគទាន និង
- នៅពេលដែលបទប្បញ្ញត្តិជាធរមាន ចែងអំពីវិធានស្តីពីដំណើរការនិងការគ្រប់គ្រងសកម្មភាពនៃបរធនបាលកិច្ច។

៣- បរធនបាលកិច្ចសង្គម ត្រូវបានបង្កើតឡើងនៅពេលដែលបរធនបាលទាយកធ្វើប្រទានកម្មទ្រព្យសម្បត្តិរបស់ខ្លួនឱ្យទៅបរធនបាល ដើម្បីប្រើប្រាស់ជាប្រយោជន៍ទូទៅក្នុងសង្គម ដូចជាក្នុងគោលបំណងវប្បធម៌ អប់រំ មនុស្សជាតិ សាសនា ឬវិទ្យាសាស្ត្រ។ បរធនបាលកិច្ចសង្គម រួមមាន៖

ក- មូលនិធិពិសេស៖

- មូលនិធិដែលបង្កើតដោយបរធនបាលទាយកតាមរយៈប្រទានកម្ម ឬមតកសាសន៍

- តាមរយៈការទទួលទ្រព្យសម្បត្តិពីអ្នកផ្តល់វិភាគទានបរធនបាលកិច្ចនៅមានជីវិតឬទទួលទ្រព្យសម្បត្តិតាមមតកសាសន៍របស់អ្នកផ្តល់វិភាគទានបរធនបាលកិច្ច និង
- ទ្រព្យសម្បត្តិត្រូវបានផ្ទេរឱ្យទៅបរធនបាល ដើម្បីបំពេញគោលបំណងជាប្រយោជន៍សង្គម និង
- មិនស្វែងរកប្រាក់ចំណេញឬគ្មានប្រតិបត្តិការជាសហគ្រាសពាណិជ្ជកម្ម និង
- លើកលែងតែមានចែងផ្សេងក្នុងលិខិតបរធនបាលកិច្ច ទ្រព្យសម្បត្តិដំបូងនិងទ្រព្យសម្បត្តិបន្ថែមផ្សេងទៀត ដែលអ្នកផ្តល់វិភាគទានបរធនបាលកិច្ចបានផ្ទេរចូលមូលនិធិណាមួយ ត្រូវរក្សាទុកដើម្បីបំពេញគោលបំណងបរធនបាលកិច្ច ហើយអនុញ្ញាតឱ្យចែកចាយតែផលដែលបានពីទ្រព្យសម្បត្តិនោះប៉ុណ្ណោះ។

ខ- មូលនិធិសម្រាប់ជាប្រយោជន៍ដល់អង្គការវប្បធម៌ អប់រំ មនុស្សជាតិ សាសនា ឬវិទ្យាសាស្ត្រ៖ ទ្រព្យសម្បត្តិទទួលពីបុគ្គល រួមមានប្រទានកម្ម ឬមតកសាសន៍ ហើយទ្រព្យសម្បត្តិនេះត្រូវបានផ្ទេរដើម្បីបម្រើគោលដៅសម្រាប់ជាប្រយោជន៍ ជាអាទិ៍ វប្បធម៌ អប់រំ មនុស្សជាតិ សាសនា ឬវិទ្យាសាស្ត្រ។

៤- បរធនបាលកិច្ចបុគ្គលត្រូវបានបង្កើតឡើងសម្រាប់ជាប្រយោជន៍របស់បរធនបាលទាយក ឬបុគ្គលដែលកំណត់ជាក់លាក់ដោយបរធនបាលទាយកតាមលក្ខខណ្ឌដូចខាងក្រោម៖

ក- បរធនបាលទាយកជារូបវន្តបុគ្គលដែលធ្វើប្រទានកម្មទ្រព្យសម្បត្តិឬមូលនិធិរបស់ខ្លួនឱ្យទៅបរធនបាលសម្រាប់ជាប្រយោជន៍របស់ខ្លួនផ្ទាល់ឬរបស់បុគ្គលផ្សេងទៀត ឬ

ខ- ការផ្ទេរទ្រព្យសម្បត្តិឬមូលនិធិ ដោយបរធនបាលទាយក៖
- ករណីបរធនបាលទាយកនៅមានជីវិត បរធនបាលទាយកនោះត្រូវធ្វើលិខិតបរធនបាលកិច្ចដោយមានការបញ្ជាក់ពីសារការី ឬមេធាវី ឬឃុំ/សង្កាត់ ឬដោយបុគ្គលផ្សេងទៀតដែលមានចែងក្នុងបទប្បញ្ញត្តិជាធរមាន
- ករណីបរធនបាលទាយកធ្វើមតកសាសន៍ នៅពេលដែលបរធនបាលទាយកនោះទទួលមរណភាព តាមរយៈមតកសាសន៍នេះ បង្កើតជាបរធនបាលកិច្ចដែលស្របតាមបទប្បញ្ញត្តិនៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា។

**ប្រការ៥ .–**

ក្រុមហ៊ុនបរធនបាលត្រូវចុះបញ្ជីពន្ធដារជាអ្នកជាប់ពន្ធមធ្យមឬអ្នកជាប់ពន្ធធំ។ ដោយឡែក បរធនបាលរូបវន្តបុគ្គលឯករាជ្យ ត្រូវចុះបញ្ជីពន្ធដារជាអ្នកជាប់ពន្ធតូច ឬអ្នកជាប់ពន្ធមធ្យម ឬអ្នកជាប់ពន្ធធំ ដោយផ្អែកលើកម្រិតផលរបរឬទ្រព្យសកម្មអាជីវកម្ម ដូចមានចែងក្នុងប្រកាសស្តីពីការកំណត់ចំណាត់ថ្នាក់អ្នកជាប់ពន្ធតាមរបបស្វ័យប្រកាស ក្នុងអំឡុងពេល ១៥ថ្ងៃ នៃថ្ងៃធ្វើការ ក្រោយពីចាប់ផ្តើមធ្វើសកម្មភាពសេដ្ឋកិច្ច ឬក្រោយពីពេលទទួលបានអាជ្ញាបណ្ណ និង/ឬការអនុញ្ញាតពីនិយ័តករបរធនបាលកិច្ច។

**ប្រការ៦ .–**

បរធនបាលត្រូវមានកាតព្វកិច្ចកាន់បញ្ជិកាគណនេយ្យដូចខាងក្រោម៖

១- ត្រូវកត់ត្រាដាច់ដោយឡែកពីគ្នារវាងបញ្ជិកាគណនេយ្យរបស់បរធនបាលនិងប្រតិបត្តិការបរធនបាលកិច្ច។ បរធនបាលត្រូវកំណត់ឱ្យបានច្បាស់លាស់នូវកម្មសិទ្ធិលើទ្រព្យសម្បត្តិ ចំណូល ចំណាយ បំណុល និងប្រតិបត្តិការផ្សេងៗសម្រាប់កត់ត្រាក្នុងបញ្ជិកាគណនេយ្យរបស់ខ្លួនឯង និងបញ្ជិកាគណនេយ្យរបស់ប្រតិបត្តិការបរធនបាលកិច្ច ដោយស្របតាមការកំណត់ក្នុងលិខិតបរធនបាលកិច្ច។

២- ត្រូវប្រើវិធានគណនេយ្យដូចមានចែងក្នុងមាត្រា៦ នៃច្បាប់ស្តីពីសារពើពន្ធ។

៣- ត្រូវរៀបចំបញ្ជីគណនេយ្យសម្រាប់ប្រតិបត្តិការបរធនបាលកិច្ចនីមួយៗដាច់ដោយឡែកពីគ្នា ក្នុងករណីបរធនបាលគ្រប់គ្រងប្រតិបត្តិការបរធនបាលកិច្ចលើសពីមួយ។

**ប្រការ៧ .-**

១- ប្រាក់ចំណូលជាប់ពន្ធ៖

ក- បរធនបាល ត្រូវជាប់ពន្ធលើប្រាក់ចំណូលចំពោះលាភការ ឬកម្រៃនានាដែលទទួលបានពីការគ្រប់គ្រងប្រតិបត្តិការបរធនបាលកិច្ច។ បរធនបាលត្រូវកត់ត្រាចំណូលទាំងនេះ និងកាត់កងជាមួយចំណាយពាក់ព័ន្ធនឹងប្រតិបត្តិការរបស់បរធនបាលក្នុងការគ្រប់គ្រងប្រតិបត្តិការបរធនបាលកិច្ច ស្របតាមវិធានទូទៅស្តីពីចំណាយដូចមានចែងក្នុងច្បាប់និងលិខិតបទដ្ឋានគតិយុត្តស្តីពីពន្ធលើប្រាក់ចំណូលជាធរមាន។

**ឧទាហរណ៍ទី១៖**

បរធនបាលទាយក បានប្រគល់អគារមួយកន្លែងទៅឱ្យក្រុមហ៊ុនបរធនបាលដើម្បីគ្រប់គ្រងនិងចាត់ចែង។ ក្រុមហ៊ុនបរធនបាល បានយកអគារនេះដាក់ជួលទៅឱ្យបុគ្គលផ្សេងទៀត ដោយទទួលបានចំណូលពីការជួលសរុបចំនួន ២០ លានរៀល ក្នុងមួយខែ ហើយក្រុមហ៊ុនបរធនបាលទទួលបានកម្រៃជើងសាចំនួន ១ លានរៀល ( ៥% នៃតម្លៃឈ្នួល ) ក្នុងមួយខែ ស្របតាមលិខិតបរធនបាលកិច្ច។

ករណីនេះ ប្រាក់កម្រៃសេវាចំនួន ១ លានរៀល ត្រូវចាត់ទុកជាប្រាក់ចំណូលជាប់ពន្ធរបស់ក្រុមហ៊ុនបរធនបាល។

ខ- បរធនជាទ្រព្យសម្បត្តិឬមូលនិធិដែលបរធនបាលទាយកបានផ្ទេរទៅឱ្យបរធនបាលចាត់ចែង គ្រប់គ្រង និងថែរក្សា តាមលក្ខខណ្ឌដែលកំណត់ដោយលិខិតបរធនបាលកិច្ចឬបទប្បញ្ញត្តិជាធរមាន គឺពុំចាត់ទុកជាប្រាក់ចំណូលនិង/ឬទ្រព្យសម្បត្តិរបស់បរធនបាលទេ។

**ឧទាហរណ៍ទី២៖**

បរធនបាលទាយក បានផ្ទេរប្រាក់ទៅឱ្យក្រុមហ៊ុនបរធនបាលចំនួន ៣០០ លានរៀល ដើម្បីទិញដីមួយកន្លែង។

ករណីនេះ ប្រាក់ចំនួន ៣០០ លានរៀល ពុំត្រូវបានចាត់ទុកជាប្រាក់ចំណូលជាប់ពន្ធរបស់ក្រុមហ៊ុនបរធនបាលទេ។

២- អត្រាពន្ធ៖

បរធនបាលត្រូវអនុវត្តអត្រាពន្ធលើប្រាក់ចំណូលដូចមានចែងនៅក្នុងមាត្រា២០ នៃច្បាប់ស្តីពីសារពើពន្ធដូចខាងក្រោម៖

ក- ២០ (ម្ភៃ) ភាគរយ ចំពោះប្រាក់ចំណូលជាប់ពន្ធដែលសម្រេចបានដោយនីតិបុគ្គល។

ខ- ជាប់ពន្ធតាមអត្រាកំណើនតាមថ្នាក់ពី ០ (សូន្យ) ភាគរយ ដល់ ២០ (ម្ភៃ) ភាគរយ ចំពោះប្រាក់ចំណូលជាប់ពន្ធដែលសម្រេចបានដោយរូបវន្តបុគ្គល សហគ្រាសឯកបុគ្គល និងចំណែកដែលត្រូវបែងចែកឱ្យសមាជិកម្នាក់ៗរបស់ក្រុមហ៊ុនសហកម្មសិទ្ធិ។

**ប្រការ៨ ._**

ទ្រព្យសម្បត្តិបរធនបាលកិច្ច ត្រូវជាប់ពន្ធស្របតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តស្តីពីពន្ធដារ មានជាអាទិ៍៖

១- ពន្ធលើថ្លៃឈ្នួលអចលនទ្រព្យ៖

ចំណូលពីការជួលអចលនទ្រព្យដែលជាទ្រព្យសម្បត្តិបរធនបាលកិច្ច ត្រូវស្ថិតក្រោមវិសាលភាពនៃពន្ធលើថ្លៃឈ្នួលអចលនទ្រព្យ។ បរធនបាលត្រូវមានកាតព្វកិច្ចកត់ត្រាចំណូលពីការជួលនោះ ដោយត្រូវគណនាពន្ធលើថ្លៃឈ្នួលអចលនទ្រព្យ និងត្រូវដាក់លិខិតប្រកាសនិងបង់ប្រាក់ពន្ធជូនរដ្ឋបាលសារពើពន្ធ ស្របតាមបទប្បញ្ញត្តិស្តីពីពន្ធលើថ្លៃឈ្នួលអចលនទ្រព្យជាធរមាន។

២- ពន្ធលើចំណេញមូលធន៖

ក្នុងករណីមានការលក់ឬផ្ទេរមូលធន ចំណូលពីការលក់ឬផ្ទេរទាំងនោះត្រូវស្ថិតក្រោមវិសាលភាពនៃពន្ធលើចំណេញមូលធន។ បរធនបាលជាអ្នកគ្រប់គ្រង និងចាត់ចែងបរធនបាលកិច្ចត្រូវមានកាតព្វកិច្ចកត់ត្រាចំណូលនៃប្រតិបត្តិការនោះ ដោយត្រូវគណនាពន្ធលើចំណេញមូលធន និងត្រូវដាក់លិខិតប្រកាសនិងបង់ប្រាក់ពន្ធជូនរដ្ឋបាលសារពើពន្ធ ស្របតាមបទប្បញ្ញត្តិស្តីពីពន្ធលើចំណេញមូលធនជាធរមាន។

**ឧទាហរណ៍ទី៣៖**

បរធនបាលទាយក បានប្រគល់ប្រាក់ទៅឱ្យក្រុមហ៊ុនបរធនបាលចំនួន ៤០០ លានរៀល ដើម្បីទិញផ្ទះមួយកន្លែងដោយដាក់ឈ្មោះក្រុមហ៊ុនបរធនបាលជាកម្មសិទ្ធិករ ឬអ្នកកាន់កាប់អចលនទ្រព្យ។ ក្រោយមកក្រុមហ៊ុនបរធនបាល បានលក់ផ្ទះនេះក្នុងតម្លៃ ៦០០ លានរៀល។ ក្រុមហ៊ុនបរធនបាល បានជ្រើសរើសយកវិធីកាត់កងចំណាយតាមការកំណត់ ដែលត្រូវបានគណនាដូចខាងក្រោម៖

| | | |
|---|---|---|
| ចំណូលពីការលក់ផ្ទះ | = | ៦០០ លានរៀល |
| ការកាត់កងចំណាយតាមការកំណត់ | = | ៨០% x ចំណូលពីការលក់ផ្ទះ |
| | = | ៨០% x ៦០០ លានរៀល |
| | = | ៤៨០ លានរៀល |
| ចំណេញមូលធន | = | ចំណូលពីការលក់ផ្ទះ - ចំណាយតាមការកំណត់ |
| | = | ៦០០ លានរៀល - ៤៨០ លានរៀល |
| | = | ១២០ លានរៀល |
| ពន្ធលើចំណេញមូលធន | = | ចំណេញមូលធន x អត្រាពន្ធ |
| | = | ១២០ លានរៀល x ២០% |
| | = | ២៤ លានរៀល។ |

៣- ពន្ធប្រថាប់ត្រា៖

ក្នុងករណី មានការផ្ទេរកម្មសិទ្ធិឬសិទ្ធិកាន់កាប់ ឬការដាក់ភាគហ៊ុនជាអចលនទ្រព្យនិងចលនទ្រព្យឬទ្រព្យសម្បត្តិបរធន ឬការផ្ទេរភាគហ៊ុន ការផ្ទេរទាំងនោះត្រូវស្ថិតក្រោមវិសាលភាពនៃពន្ធប្រថាប់ត្រា។ បរធនបាលជាអ្នកគ្រប់គ្រង និងចាត់ចែងបរធនបាលកិច្ច ត្រូវមានកាតព្វកិច្ចកត់ត្រាចំណូលពីប្រតិបត្តិការនោះ និងត្រូវដាក់លិខិតប្រកាសនិងបង់ប្រាក់ពន្ធជូនរដ្ឋបាលសារពើពន្ធ ស្របតាមបទប្បញ្ញត្តិស្តីពីពន្ធប្រថាប់ត្រាជាធរមាន។

**ឧទាហរណ៍ទី៤៖**

បរធនបាលទាយក បានប្រគល់ប្រាក់ចំនួន ៧០០ លានរៀល ទៅឱ្យក្រុមហ៊ុនបរធនបាលដើម្បីគ្រប់គ្រង និងចាត់ចែង។ ក្រុមហ៊ុនបរធនបាល បានយកប្រាក់នេះទៅទិញដីមួយកន្លែងពីបុគ្គលផ្សេងទៀត ដោយដាក់ឈ្មោះក្រុមហ៊ុនបរធនបាលជាកម្មសិទ្ធិករ។ ក្នុងករណីនេះ ក្រុមហ៊ុនបរធនបាល គឺជាអ្នកទិញដែលត្រូវទទួលបន្ទុកក្នុងការបង់ពន្ធប្រថាប់ត្រា ដូចខាងក្រោម៖

ពន្ធប្រថាប់ត្រា = តម្លៃដី x អត្រាពន្ធ
= ៧០០ លានរៀល x ៤%
= ២៨ លានរៀល។

៤- ពន្ធកាត់ទុក៖

ក- ការបង្វែរប្រាក់ចំណូលក្រោយបង់ពន្ធឱ្យទៅអ្នកជាប់ពន្ធអនិវាសនជន គឺជាកម្មវត្ថុនៃពន្ធកាត់ទុក។ ប៉ុន្តែ ក្នុងករណីដែលប្រាក់ចំណូលនោះបានបង់ពន្ធលើចំណេញមូលធនរួចហើយ គឺមិនមែនជាកម្មវត្ថុនៃពន្ធកាត់ទុកទៀតទេ។

ខ- បរធនបាលជាអ្នកគ្រប់គ្រង និងចាត់ចែងបរធនបាលកិច្ច ត្រូវមានកាតព្វកិច្ចកត់ត្រាប្រតិបត្តិការក្នុងបញ្ជីគណនេយ្យរបស់ប្រតិបត្តិការបរធនបាលកិច្ច ដោយត្រូវគណនាពន្ធកាត់ទុក និងត្រូវដាក់លិខិតប្រកាសនិងបង់ប្រាក់ពន្ធជូនរដ្ឋបាលសារពើពន្ធ ស្របតាមបទប្បញ្ញត្តិស្តីពីពន្ធកាត់ទុកជាធរមាន។

**ឧទាហរណ៍ទី៥៖**

បរធនបាលទាយកជាអនិវាសនជន បានប្រគល់ប្រាក់ទៅឱ្យក្រុមហ៊ុនបរធនបាលចំនួន ៤០០ លានរៀល ដើម្បីទិញផ្ទះមួយកន្លែងដោយដាក់ឈ្មោះក្រុមហ៊ុនបរធនបាលជាកម្មសិទ្ធិករ។ ក្រោយមកក្រុមហ៊ុនបរធនបាលបានលក់ផ្ទះនេះក្នុងតម្លៃ ៦០០ លានរៀល និងបានបង់ពន្ធលើចំណេញមូលធន ចំនួន ២៤ លានរៀល ដោយផលចំណេញត្រូវផ្ទេរទៅឱ្យបរធនបាលទាយកវិញ។

ផលចំណេញពីការលក់ផ្ទះ: = ថ្លៃលក់ - ថ្លៃទិញ - ប្រាក់ពន្ធលើចំណេញមូលធន
= ៦០០ - ៤០០ - ២៤
= ១៧៦ លានរៀល។

ក្រុមហ៊ុនបរធនបាលដែលបានផ្ទេរផលចំណេញទៅបរធនបាលទាយកជាអនិវាសនជន មិនត្រូវអនុវត្តពន្ធកាត់ទុកតាមអត្រា ១៤% ទៅលើផលចំណេញពីការលក់ចំនួន ១៧៦ លានរៀល ទៀតទេ។

**ប្រការ៩ ._**

ក្រៅពីកាតព្វកិច្ចសារពើពន្ធដូចមានចែងក្នុងប្រការ៧ និងប្រការ៨ នៃប្រកាសនេះ បរធនបាលជាអ្នកគ្រប់គ្រង ចាត់ចែង និងថែរក្សាបរធន ត្រូវមានកាតព្វកិច្ចបង់ពន្ធអាករដទៃទៀត ស្របតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តស្តីពីពន្ធដារជាធរមាន។

**ប្រការ១០ ._**

បទប្បញ្ញត្តិស្តីពីការលើកលែងពន្ធអាករដែលមានចែងចំពោះប្រភេទពន្ធអាករណាមួយ ត្រូវអនុវត្តផងដែរចំពោះទ្រព្យសម្បត្តិបរធនបាលកិច្ចដែលពាក់ព័ន្ធនឹងប្រភេទពន្ធអាករនោះ។

**ប្រការ១១ .-**

បរធនបាលត្រូវមានកាតព្វកិច្ចដាក់លិខិតប្រកាសនិងបង់ប្រាក់ពន្ធតាមការកំណត់របស់រដ្ឋបាលសារពើពន្ធស្របតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តស្ដីពីពន្ធដារជាធរមាន។

**ប្រការ១២ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ១៣ .-**

រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី នាយកខុទ្ទកាល័យ អគ្គលេខាធិការ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋាន ឬអគ្គនាយកនៃគ្រប់អគ្គនាយកដ្ឋាន អគ្គាធិការនៃអគ្គាធិការដ្ឋាន និងប្រធានអង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ[illegible] ខែ[illegible] ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី[illegible] ខែ[illegible] ឆ្នាំ២០២៥

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន

**កន្លែងទទួល៖**

- ទីស្ដីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្ដេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្ដមឧបនាយករដ្ឋមន្ត្រី
- រដ្ឋបាលរាជធានី ខេត្ត
- ដូចប្រការ១៣ "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ